

ការ ធ្វើតាមព្រះយេស៊ូនៅ

# ប្រទេសឥណ្ឌូនេស៊ី



ជួបជាមួយ ដើរ៉ាហាមី !



## អំពីដើរ៉ាហាមី

អាយុ ៖ ១១ឆ្នាំ

មកពី ៖ ហ្សារ៉ា ខាងលិច ប្រទេសឥណ្ឌូណេស៊ី

ភាសា ៖ ភាសាឥណ្ឌូណេស៊ី

គោលដៅ និង ក្តីសុបិន ៖
១ ) ក្លាយជាមន្ត្រីប៉ូលីស ។
២ ) រៀនពីរបៀបរៀបចំបាច់ផ្កា ។
៣ ) អានព្រះគម្ពីរមរមនទាំងមូល ។

ក្រុមគ្រួសារ ៖ ដើរ៉ាហាមី ម៉ាក់ ប៉ា បងស្រីម្នាក់ និង បងប្រុសពីរនាក់ ។

## របៀបដែលដើរ៉ាហាមី ធ្វើតាមព្រះយេស៊ូវ

ដើរ៉ាហាមី និយាយថា ៖ « ខ្ញុំចូលចិត្តជួយឪពុកម្តាយរបស់ខ្ញុំក្នុងរបៀបតូចៗ » ។ នាងជួយពួកគាត់នៅពេលនាងសំអាតបន្ទប់របស់នាង និងរៀបចំគ្រែគេងជារៀងរាល់ព្រឹក ។ នាងក៏ជួយបោស និងជូតផ្ទះរបស់ពួកគេផងដែរ ។

ដើរ៉ាហាមី និយាយថា ៖ « ការបម្រើឪពុកម្តាយរបស់ខ្ញុំធ្វើឲ្យខ្ញុំរីករាយណាស់ » ។ « ខ្ញុំបង្ហាញសេចក្តីស្រឡាញ់របស់ខ្ញុំចំពោះព្រះយេស៊ូវគ្រីស្ទតាមរយៈការជួយពួកគាត់ » ។ ●

Illustrations by Steliyana Doneva



### អ្នកក៏អាចធ្វើតាមព្រះយេស៊ូវបានដែរ !

មានវិធីជាច្រើនដើម្បីធ្វើតាមព្រះយេស៊ូវ ។ តើអ្នកធ្វើតាមទ្រង់តាមរបៀបណា ? សូមសរសេរប្រាប់យើងផង !

## ចំណង់ចំណូលចិត្តរបស់ដើរ៉ាហាមី

ដំណើររឿងក្នុងព្រះគម្ពីរ ៖
នៅពេលព្រះយេស៊ូវគ្រីស្ទបានប្រសូតនៅភូមិបេថ្លេហិម



ទីកន្លែង ៖
មាត់សមុទ្រ



ផ្លែឈើ និងបន្លែ ៖
ផ្លែចេក ផ្លែឪឡឹក ការ៉ុត និងផ្កាខាត់ណាខៀវ

ពណ៌ ៖
ពណ៌ក្រហម និងពណ៌ខៀវ



មុខវិជ្ជានៅសាលា ៖
គណិតវិទ្យា